# ការរើសអើង គឺប្រឆាំងទៅនឹងច្បាប់!

ច្បាប់សហព័ន្ធ ការពារដល់លោកអ្នក ហើយនិងប្រជាពលរដ្ឋផ្សេងទៀតអំពីបញ្ហាការរើសអើងចេញពីកម្មវិធីការងារ អង្គការ ឬ ការិយាល័យមួយចំនួន ឬ ទាំងអស់ដែលលោកអ្នកកំពុងអាននូវប័ណ្ណប្រកាស ឬ ឯកសារផ្សព្វផ្សាយនេះ។ មជ្ឈមណ្ឌលទទួលបន្ទុកសិទ្ធិពលរដ្ឋ (ដែលគេស្គាល់ ឬ ហៅកាត់ថា៖ "CRC") នៃក្រសួងការងារសហរដ្ឋអាមេរិក មានបន្ទុកមើលការខុសត្រូវលើបញ្ហាច្បាប់អស់ទាំងនេះ។

វាមិនមានបញ្ហាអ្វីទេ ប្រសិនបើលោកអ្នកជាអតិថិជនម្នាក់ដែលមានបំណងចង់ ឬ ចាំបាច់ត្រូវការសេវាកម្ម និយោកជិក បំពេញការងារម្នាក់របស់ក្រុមហ៊ុន អង្គការ ឬ ការិយាល័យ មនុស្សម្នាក់ដែលដាក់ពាក្យស្នើសុំការងារ ឬ សមាជិក/ សមាជិកាផ្នែកសាធារណ:។ ប្រសិនបើលោកអ្នកមានទំនាក់ទំនងជាមួយនឹងកម្មវិធីមួយដែលមានធានារ៉ាប់រងដោយច្បាប់ណាមួយនោះ កម្មវិធីនេះមិនអាចរើសអើងប្រឆាំងនឹងលោកអ្នកបានទេ។

CRC បានរៀបចំនូវប័ណ្ណប្រកាសនេះឡើង ប្រយោជន៍ពន្យល់ដូចខាងក្រោមនេះ៖

- អ្វីដែលសិទ្ធិលោកអ្នកមាន ហើយនិង
- ទីកន្លែងដែលលោកអ្នកអាចដាក់ពាក្យបណ្តឹងបាន ប្រសិនបើលោកអ្នកជឿជាក់ថា ច្បាប់នេះត្រូវបានគេបំពាន។

---

## *ប្រភេទនៃការរើងអើងទាំងនេះ គឺប្រឆាំង ឬ ផ្ទុយទៅនឹងច្បាប់*

កម្មវិធីមួយដែលស្ថិតនៅក្រោមច្បាប់ត្រឹមត្រូវដូចដែលបានលើកឡើងនៅខាងដើមបំផុតនៃប័ណ្ណប្រកាសនេះ មិនមានការអនុញ្ញាតិឲ្យរើសអើងលើមូលដ្ឋានណាមួយដូចខាងក្រោមនេះទេ (**ប្រភេទនៃការរើសអើង**)[1]:

ចំពោះអតិថិជន បេក្ខជន (អ្នកដាក់ពាក្យសុំ) និយោជិក និង ពលរដ្ឋទូទៅ:

- **ពូជសាសន៍**
- **វណ្ណ:(ពណ៌សម្បុរ)**
- **ដើមកំណើតជនជាតិ**
- **សាសនា**
- **ពិការភាព**
- **ទំនាក់ទំនងនយោបាយ ឬ ជំនឿ**
- **ភេទ**
- **អាយុ**

**សម្រាប់តែអតិថិជនតែប៉ុណ្ណោះ**

- **សិទ្ធិពលរដ្ឋ ឬ ស្ថានភាពធ្វើការងារស្របច្បាប់នៅសហរដ្ឋអាមេរិក**
- **ដោយស្ថិតជាផ្នែកមួយនៃកម្មវិធីទាំងឡាយណាដែលទទួលបានប្រភេទ "ជំនួយជាក់លាក់" អំពីរដ្ឋាភិបាលសហព័ន្ធក្រោមច្បាប់មួយដ៏ជាក់លាក់ (ច្បាប់វិនិយោគលើកម្លាំងការងារ)**

## តើខ្ញុំអាចដាក់ពាក្យ បណ្តឹងមួយស្តីពីបញ្ហាការរើសអើងបានយ៉ាងដូចម្តេច?

ក្នុងករណីដែលលោកអ្នក គិតឃើញថា:

- កម្មវិធីមួយនៃការងារនេះ អង្គការ ឬ ការិយាល័យមួយបានប្រព្រឹត្តការរើសអើងប្រឆាំងនឹងលោកអ្នក ឬ ប្រឆាំងទៅនឹងក្រុមមនុស្សណាមួយជាក់លាក់ និង
- ប្រភេទនៃការរើសអើងដែលលោកអ្នកគិតឃើញថា បានកើតមានឡើងនោះ ស្ថិតក្នុងបញ្ជីដែល

លោកអ្នកនឹងត្រូវស្វែងរកកន្លែងផ្សេងទៀតនៅលើប័ណ្ណប្រកាសនេះ បន្ទាប់មកលោកអ្នកមានសិទ្ធិដាក់ពាក្យបណ្តឹងស្តីពីបញ្ហាការរើសអើងនេះបាន។.

## តើមានកម្រិតពេលវេលាទេ សម្រាប់ការដាក់ពាក្យបណ្តឹងនេះ?

បាទ/ចាស(ពិតណាស់!)។ លោកអ្នក *ត្រូវតែ*ដាក់ពាក្យបណ្តឹងមួយស្តីពីការរើសអើងក្នុងរយ:ពេល 180ថ្ងៃចាប់ពីថ្ងៃដែលការរើសអើងនោះកើតមានឡើង។ មានតែមនុស្សមនុស្សម្នាក់ប៉ុណ្ណោះដែលអាចអនុញ្ញាតិឲ្យលោកអ្នកដាក់ពាក្យបណ្តឹងរបស់លោកអ្នកយឺតយ៉ាវ គឺនាយកមជ្ឈមណ្ឌលទទួលបន្ទុកកិច្ចការសិទ្ធិពលរដ្ឋ (CRC) នៅ Washington, DC។ ក្នុងករណីដែលលោកអ្នក ចង់ដាក់ពាក្យបណ្តឹងស្តីពីបញ្ហាការរើងអើងនេះក្រោយរយ:ពេល 180ថ្ងៃ លោកអ្នកត្រូវតែសរសេរលិខិតទៅកាន់នាយក CRC ដោយពន្យល់អំពីមូលហេតុដែលលោកអ្នកទទួលបានការអនុញ្ញាតិដាក់ពាក្យបណ្តឹងរបស់លោកអ្នកយឺតពេល ហើយស្នើសុំការអនុញ្ញាតិ។ សូមរកមើលអាស័យដ្ឋានរបស់ CRC នៅលើប័ណ្ណប្រកាសនេះ។

## តើពាក្យបណ្តឹងនេះ គួរសរសេរបញ្ចូលនូវអ្វីខ្លះ?

ពាក្យបណ្តឹងនេះ *ត្រូវតែ*ទទួលបានការបំពេញជាលាយល័ក្ខអក្សរ (ឬ ផ្លូវការ)។ ពាក្យបណ្តឹង គួរសរសេរបញ្ចូលនូវខ្លឹមសារដូចខាងក្រោមនេះ

- **ឈ្មោះរបស់លោកអ្នក**
- **អាស័យដ្ឋានរបស់លោកអ្នក**
- **ហត្ថលេខារបស់លោកអ្នក**
- **ឈ្មោះ និង អាស័យដ្ឋានរបស់កម្មវិធី កន្លែងការងារ អង្គការ ឬ ការិយាល័យដែលលោកអ្នកគិតឃើញថាបានបង្កើតឲ្យការរើសអើងប្រឆាំងទៅនឹងលោកអ្នក ឬ ប្រឆាំងទៅនឹងក្រុមមនុស្សណាមួយដ៏ជាក់លាក់**
- **កាលបរិច្ឆេទដែលលោកអ្នកគិតឃើញថាការរើសអើងនោះបានកើតមានឡើង។**
- **ប្រភេទនានានៃការរើសអើងដែលលោកអ្នកគិតឃើញថា មានជាប់ពាក់ព័ន្ធនៅក្នុងករណីនេះ (ឧទាហរណ៍: ជាតិសាសន៍ ភេទ ពិការភាព អាយុ)។**

ឈ្មោះរបស់មនុស្សទាំងឡាយណាដែលមានជាប់ពាក់ព័ន្ធនៅក្នុងបញ្ហានៃការរើសអើង ដែលមានជាអាទិ៍: សាក្សីនានាដែលបានឃើញផ្ទាល់។ លើសពីនេះ លោកអ្នកត្រូវតែពន្យល់អំពីអ្វីដែលបានកើតមានឡើង និង អំពីមូលហេតុដែលលោកអ្នកគិតឃើញថាមានបញ្ហាការរើសអើងនេះកើតមានឡើង។

## តើខ្ញុំត្រូវដាក់ពាកយបណ្តឹងនេះដោយខ្លួនឯងផ្ទាល់ឬ?

លោកអ្នក អាចនឹងដាក់ពាក្យបណ្តឹងនេះបានតាមរយ:"មនុស្សតំណាង។" តំណាងរបស់លោកអ្នក អាចជាអ្នកច្បាប់(មេធាវី) សមាជិកសមាជិកាក្នុងគ្រួសារ អ្នកធ្វើការងារសង្គម អ្នកបម្រើការងារក្នុងសហជីពម្នាក់ ឬ អ្នកណាម្នាក់ផ្សេងទៀតដែលលោកអ្នកសម្រេចជម្រើសរើសឲ្យដាក់ពាក្យបណ្តឹងជំនួសខ្លួន។ ប្រសិនបើតំណាងម្នាក់ ដាក់ពាក្យបណ្តឹងជំនួសលោកអ្នក ចំណុចសំខាន់ទាំងបីនេះ ត្រូវតែមាននៅលើបណ្តឹង។:

- **ទីមួយ ឈ្មោះនៃតំណាងរបស់លោកអ្នក ត្រូវតែមានសរសេរនៅលើពាក្យបណ្តឹងនោះ។**
- **ទីពីរ ពាក្យបណ្តឹងនោះ ត្រូវតែនិយាយរៀបរាប់ថា តំណាងរបស់លោកអ្នកនឹងដាក់ពាក្យបណ្តឹងជំនួសឲ្យលោកអ្នក។**
- ទីបី លោកអ្នកត្រូវតែចុះហត្ថលេខាលើពាក្យបណ្តឹងនោះដោយខ្លួនឯងផ្ទាល់។

## តើខ្ញុំអាចដាក់ពាក្យបណ្តឹងមួយបាននៅកន្លែងណា?

លោកអ្នក អាចសម្រេចចិត្តជ្រើសរើសកន្លែងមួយក្នុងចំណោមកន្លែងចំនួនពីរដែលអាចធ្វើទៅបាន ប្រយោជន៍ដាក់ពាក្យបណ្តឹងរបស់លោកអ្នកបាន។:

អាជ្ញាធរថ្នាក់រដ្ឋ ឬ តាមមូលដ្ឋាន។ ប្រសិនបើលោកអ្នក ចង់ដាក់ពាក្យបណ្តឹងរបស់លោកអ្នកជាមួយអាជ្ញាធរថ្នាក់រដ្ឋ ឬ តាមមូលដ្ឋាន នេះគឺជាព័ត៌មានទំនាក់ទំនងសម្រាប់ការិយាល័យដែលត្រូវដាក់ពាក្យបណ្តឹង:

**[សូមសរសេរត្រង់ចន្លោះនេះនូវ**
**អាស័យដ្ឋាន និង ព័ត៌មានទំនាក់ទំនងផ្សេងទៀត**
**សម្រាប់ការដាក់ពាក្យបណ្តឹងមួយនៅឯ**
**អាជ្ញាធរថ្នាក់រដ្ឋ ឬ តាមមូលដ្ឋាន]**

**មជ្ឈមណ្ឌលទទួលបន្ទុកសិទ្ធិពលរដ្ឋនៃរដ្ឋាភិបាលសហព័ន្ធ។** ប្រសិនបើលោកអ្នកចង់ដាក់ពាក្យបណ្តឹងរបស់ខ្លួននៅមជ្ឈមណ្ឌលទទួលបន្ទុកសិទ្ធិពលរដ្ឋ សូមមេត្តាផ្ញើវាទៅកាន់អាស័យដ្ឋានដូចខាងក្រោមនេះ៖

**ក្រសួងការងារសហរដ្ឋអាមេរិក**
**មជ្ឈមណ្ឌលទទួលបន្ទុកសិទ្ធិពលរដ្ឋ**
200 Constitution Ave. NW
Room N4123
Washington, DC 20210

ប្រសិនបើលោកអ្នក មានចម្ងល់ណាមួយ លោកអ្នកអាចទាក់ទងមកកាន់ការិយាល័យ CRC តាមរយ:ទូរស័ព្ទ ឬ សារអេឡិចត្រូនិក(អ៊ីម៉ែល)បានតាមលេខទូរស័ព្ទឬអាស័យដ្ឋានដូចខាងក្រោមនេះ៖

ទូរស័ព្ទ: (202) 693-6500
TTY/TDD: (202) 693-6516
អ៊ីម៉ែល: CivilRightsCenter@dol.gov
ឬ មើលគេហទំព័ររបស់ CRC:
http://www.dol.gov/oasam/programs/crc

ម៉ោងការងាររបស់ CRC គឺចាប់ពីម៉ោង 9ព្រឹកដល់ 5ល្ងាច ម៉ោងនៅភាគខាងកើត។

## តើខ្ញុំចាំបាច់ត្រូវប្រើប្រាស់ទម្រង់បែបបទពិសេសដើម្បីដាក់ពាក្យបណ្តឹងនេះដែរឬទេ?

- ប្រសិនបើលោកអ្នកដាក់ពាក្យបណ្តឹងនៅការិយាល័យ CRC លោកអ្នកមិនចាំបាច់ត្រូវប្រើប្រាស់ទម្រង់បែបបទពិសេសនៅលើកទីមួយនោះទេ។ លោកអ្នកគ្រាន់តែចាំបាច់ធ្វើឲ្យប្រាកដថាត្រូវបញ្ជូនមកកាន់យើងខ្ញុំនូវរាល់ខ្លឹមសារព័ត៌មានដែលមាននៅលើបញ្ជីនៅក្នុងផ្នែកនៃប័ណ្ណប្រកាសនេះដែលសរសេរថា៖ "តើពាក្យបណ្តឹងត្រូវសរសេរបញ្ចូលនូវអ្វីខ្លះ?"។ ប៉ុន្តែ ប្រសិនបើលោកអ្នកមិនប្រើប្រាស់ទម្រង់បែបបទបណ្តឹងរបស់យើងខ្ញុំទេនោះ យើងខ្ញុំនឹងសុំឲ្យលោកអ្នកបំពេញបែបបទមួយច្បាប់ នៅមុនពេលយើងខ្ញុំចាប់ផ្តើមដំណើរការបណ្តឹងរបស់លោកអ្នក។
- ប្រសិនបើលោកអ្នកចង់ដាក់ពាក្យបណ្តឹងរបស់ខ្លួនជាមួយនឹងអាជ្ញាធរថ្នាក់រដ្ឋ ឬ តាមមូលដ្ឋាន លោកអ្នកក៏មិនចាំបាច់ត្រូវប្រើប្រាស់ទម្រង់បែបបទនាពេលដំបូងនោះដែរ។ ប៉ុន្តែការិយាល័យដែលលោកអ្នកដាក់ពាក្យបណ្តឹងរបស់ខ្លួននោះ ក៏អាចសុំឲ្យលោកអ្នកបំពេញទម្រង់បែបបទចាប់ពីមួយច្បាប់ឡើងទៅដែរ មុនពេលបុគ្គលិករបស់គេចាប់ដំណើរការលើបណ្តឹងរបស់លោកអ្នក។ សូមមេត្តាប្រើប្រាស់ព័ត៌មានទំនាក់ទំនងខាងលើនេះ ប្រយោជន៍ពិនិត្យរកមើលនៅការិយាល័យនោះ។

## តើខ្ញុំអាចទទួលបានទម្រង់បែបបទដាក់បណ្តឹងរបស់ CRC នោះបានទេ

- តើលោកអ្នកអាចមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណែតដើម្បីបោះពុម្ពចេញនូវទម្រង់បែបបទនានានោះទេ? តើលោកអ្នកអាចមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណែតដើម្បីបោះពុម្ពចេញនូវទម្រង់បែបបទនានានោះទេ? ប្រសិនបើអាច គេហទំព័រ CRC មានសំណៅទម្រង់បែបបទបណ្តឹងនេះ តាមរយ:តំណភ្ជាប់:

http://www.dol.gov/oasam/programs/crc/CIFmain.htm

- ប្រសិនបើលោកអ្នក មិនមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណែតដើម្បីបោះពុម្ពចេញនូវទម្រង់បែបបទនានាទេនោះ លោកអ្នកអាចទទួលបានទម្រង់បែបបទបណ្តឹងនេះ តាមរយ:វិធីចំនួនបីដូច:
  - o លោកអ្នក អាចសរសេរលិខិតទៅកាន់ការិយាល័យ CRC ដើម្បីស្នើសុំទម្រង់បែបបទនេះមួយច្បាប់បាន។ សូមរកមើលអាស័យដ្ឋានផ្ញើសំបុត្ររបស់ CRC នៅលើប័ណ្ណប្រកាសនេះ។.
  - o អង្គភាពការងារ អង្គការ ឬ ការិយាលដែលលោកអ្នកកំពុងអានប័ណ្ណប្រកាសនេះ នឹងអាចមានលទ្ធភាពផ្តល់ជូនលោកអ្នកនូវទម្រង់បែបបទនេះចំនួនមួយច្បាប់។.

---

[1] បញ្ជីនេះ ត្រូវបានគេហៅថា៖ "ប្រភេទនៃការរើសអើងទាំងនេះ គឺប្រឆាំងទៅនឹងច្បាប់។" លោកអ្នក នឹងត្រូវរកឃើញបញ្ជីនេះនៅលើផ្នែកមួយផ្សេងទៀតនៃប័ណ្ណប្រកាសនេះ។

# ត្រូវយល់ដឹងអំពីសិទ្ធិរបស់លោកអ្នក!